ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆមាសទី១ ឆ្នាំ២០២០ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងឆមាសទី១ ឆ្នាំ២០២០នេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាធ្វើការដាំដុះបានចំនួន ១ ៥៧៤ ៨១៨ហ.ត ស្មើនឹង៦០,៨៥% នៃផែនការចំនួន ២ ៥៨៨ ១៣០ហ.ត និងស្ថានភាពទឹកភ្លៀងធ្លាក់នៅក្នុងតំបន់ពីកម្រិតខ្សោយទៅបង្គួរ នៅតាមរាជធានី-ខេត្ត។ រីឯការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀតជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល ក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកប ដោយប្រសិទ្ធភាព។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបាន ប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងឆមាសទី១ ឆ្នាំ២០២០ នេះ គឺ បានរៀបចំកិច្ចប្រជុំសំខាន់ៗ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២០ រួមទាំងការចូលរួមអនុវត្ត កំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងឆមាសទី១ ឆ្នាំ២០២០នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ លទ្ធផលផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សា

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាគិតត្រឹមថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ០៤០ ៨២៤ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៧ ៦៤៣ហ.ត និងដោយគ្រឿងយន្តមានចំនួន ២ ០៣៣ ១៨១ហ.ត លើសឆ្នាំមុនចំនួន ៤៩២ ០៩០ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ៤ ៨២៨ហ.ត តិចជាងឆ្នាំមុនចំនួន ១ ៧២១ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ១ ៥៧៤ ៨១៨ហ.ត ស្មើនឹង៦០,៨៥% នៃផែនការចំនួន ២ ៥៨៨ ១៣០ហ.ត លើសឆ្នាំមុនចំនួន ២៩០ ៨៥៦ហ.ត។

#### ១.២ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវវស្សា

-ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ៤១ ០៧៧ហ.ត ស្មើនឹង៨៣,១២% នៃផែនការចំនួន ៤៩ ៤២០ហ.ត លើសឆ្នាំមុនចំនួន ៩ ៩៥៨ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៥៩៦ ៨៤៩ហ.ត ស្មើនឹង៦៨,២៤% នៃផែនការចំនួន ៨៧៤ ៥៩៥ហ.ត លើសឆ្នាំមុនចំនួន ២៧ ៨៩៩ហ.ត។

#### ១.៣ ការនាំចេញអង្ករ

បរិមាណនាំចេញអង្ករបានចំនួន ៣៩៧ ៦៦០តោន មានការកើនឡើងចំនួន ១១៦ ១២២តោន (+៤១,២៥%) ច្រើន ជាងបរិមាណនាំចេញក្នុងឆមាសទី១ ឆ្នាំ២០១៩ ចំនួន ២៨១ ៥៣៨តោន និងនាំចេញទៅកាន់ទិសដៅចំនួន ៥៦ប្រទេស ក្នុង

នោះប្រទេសចិនលំដាប់ទី១ (១៤៧ ៩៤៩តោន) ប្រទេសបារាំងលំដាប់ទី២ (៥១ ១៧៥តោន) ប្រទេសហ្គាបុងលំដាប់ទី៣ (២៣ ៦៩១តោន) ប្រទេសម៉ាឡេស៊ីលំដាប់ទី៤ (២១ ៩០៤តោន) ប្រទេសអូស្ត្រាលីលំដាប់ទី៥ (១៨ ៨១៩តោន) ប្រទេសណេដឺឡែនលំដាប់ទី៦ (១៦ ០២៦តោន) ប្រទេសវៀតណាមលំដាប់ទី៧ (១២ ៨៣៦តោន) ប្រទេសអង់គ្លេសលំដាប់ទី៨ (១០ ៥៣៤តោន) ប្រទេសប៉ូឡូញលំដាប់ទី៩ (៩ ៩៤៥តោន) និងប្រទេសប្រ៊ុយណេលំដាប់ទី១០ (៩ ៤៥០តោន) ហើយបច្ចុប្បន្នក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន ៦៦ក្រុមហ៊ុន។

## ២ ផ្នែកផលិតកម្មកៅស៊ូ

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ៧០១ហ.ត ក្នុងនោះ ផ្ទៃដីចៀរជ័រចំនួន ២៥០ ១០៧ហ.ត ស្មើនឹង៦២% និងផ្ទៃដីថែទាំចំនួន ១៥៤ ៥៩៤ហ.ត ស្មើនឹង៣៨%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូសម្រេចបានចំនួន ៩៧ ៩៣៦តោន កើនឡើងចំនួន ១៥ ២៥៨តោន ស្មើនឹង១៨% ធៀបធៀបឆមាសទី១ ឆ្នាំ២០១៩។

### ២.៣ ការនាំចេញកៅស៊ូ

- បរិមាណបញ្ចេញលក់សម្រេចបានចំនួន ៩៧ ១៧៥តោន បានកើនឡើងចំនួន ១៤ ៤៤៧តោន ស្មើនឹង១៧% ធៀបឆមាសទី១ ឆ្នាំ២០១៩។

### ២.៤ តម្លៃកៅស៊ូ

- តម្លៃលក់មធ្យមក្នុងខែមិថុនា គឺ ១ ១៩៣ដុល្លារ/តោន កើនឡើងចំនួន ៥ដុល្លារ/តោន ស្មើនឹង០,៤៣% ធៀបខែមុន និងថយចុះចំនួន ២១០ដុល្លារ/តោន ស្មើនឹង១៥% បើធៀបខែមិថុនា ឆ្នាំ២០១៩
- តម្លៃលក់មធ្យមក្នុងឆមាសទី១ គឺ ១ ៣១៤ដុល្លារ/តោន បានថយចុះចំនួន ៩ដុល្លារ/តោន ស្មើនឹង១% ធៀបឆមាសទី១ ឆ្នាំ២០១៩
- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារចម្ការក្នុងខែមិថុនា គឺទឹកជ័រ (DRC 100%) មានការប្រែប្រួលពី ៤ ០០០៛/គ.ក្រ ដល់ ៤ ៦៧៥៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ១ ៧៣៨៛/គ.ក្រ ដល់ ២ ១០០៛/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- បានទាញយករូបភាពផ្កាយរណប (Landsat8) ឆ្នាំ២០១៩ ចំនួន ២៧ផ្ទាំង (Landsat8) ឆ្នាំ២០២០ ចំនួន ២២ផ្ទាំង និង Sentinel2 ឆ្នាំ២០២០ ចំនួន ១០ផ្ទាំងសម្រាប់វាយតម្លៃគម្របព្រៃឈើឆ្នាំ២០២០
- បានស្នើសុំប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងព្រៃសហគមន៍ចំនួន ៥កន្លែងមានផ្ទៃដីសរុបទំហំ ៣ ៨៩០,៣៦ហ.ត ស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ
- បានចុះពិនិត្យ និងផ្ទៀងផ្ទាត់តំបន់សក្តានុពលព្រៃសហគមន៍ចំនួន ៥កន្លែង មានផ្ទៃដីសរុបទំហំ ១ ២៣៦,១៩ហ.ត ស្ថិតនៅខេត្តកំពង់ស្ពឺ ស្វាយរៀង និងខេត្តកំពត
- បានចុះផ្សព្វផ្សាយស្តីពីការគ្រប់គ្រងព្រៃឈើចំនួន ៣កន្លែងមានសហគមន៍ព្រៃឈើប្រាំបីមុម សហគមន៍ព្រៃឈើរំដួលថ្មី និងសហគមន៍ព្រៃឈើដីក្រហមគិរីវ័ន្ត ខេត្តកំពង់ស្ពឺមានអ្នកចូលរួមចំនួន ១៩៣នាក់ (ស្រី១១៤នាក់)
- បានផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្ត និងយានយន្តជូនក្រុមហ៊ុនចំនួន ១០ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ២នាក់ មានរណារយន្តចំនួន ១២៥គ្រឿង និងយានយន្តចំនួន ១១៦គ្រឿង
- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ៥ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ១១នាក់ ក្នុងនោះឈើហ៊ុបមូលចំនួន ៤ ៥៩៦ម៣ ឈើអារចំនួន ៦ ៤២៣ម៣ ឈើជ្រុងចំនួន ១ ៤៩១ម៣ ក្រាក់ចំនួន ៦៣ម៣ គល់ឈើចំនួន ៤ម៣ កូនក្រឡឹងចំនួន ៥២ដើម កូនឈើចំនួន ១០១ ៧៦៨ដើម បង្គោលក្រាក់ចំនួន ៣១១ដើម ជន្លង់ម្រេចចំនួន ១៦៣ដើម ចំនៀរឈើចំនួន ១៣១ដើម អុសចម្រុះចំនួន ២៤ ៦៤៩ស្ទែរ ជ័រទឹកចំនួន ៥១៨តោន ឫស្សីព្រៃ-ឬល្លៃចំនួន ៧៣៩តោន ពកចំនួន ២០៤គ.ក្រ គល់ឈើចំនួន ៩ ៣៧៦គ.ក្រ ធ្យូងចំនួន ៤១ ៨៥៥គ.ក្រ ផ្តៅចំនួន ៣ ០០០គ.ក្រ ប្រះព្រៅចំនួន ២ ៧៨០គ.ក្រ តុចំនួន ១គ្រឿង ទូចំនួន ៨គ្រឿង កៅអីចំនួន ១២គ្រឿង គ្រែចំនួន ៤គ្រឿង សន្លឹកទ្វារចំនួន ២១សន្លឹក ចំនៀរឈើចំនួន ៣ ១១០សន្លឹក ថូផ្កាចំនួន ៤គ្រាប់ និងគ្រោងទ្វារចំនួន ៤វង់។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- បានចុះសិក្សាស្រាវជ្រាវ និងតាមដានវត្តមានសត្វព្រៃចំនួន ២លើកនៅតំបន់សហគមន៍ព្រៃឈើ អណ្តូងព្រះនាង ខេត្តរតនគីរី និងតំបន់សហគមន៍កំពង់ស្រណោះ ខេត្តព្រះវិហារដោយកត់ត្រានូវថនិកសត្វចំនួន ៧៤ប្រភេទ បក្សីចំនួន ១៣០ប្រភេទ និងឧរង្គសត្វចំនួន ៧៣ប្រភេទ

- បានចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ៦៩ច្បាប់ ក្នុងនោះ ៦៦ច្បាប់សម្រាប់ ថែរក្សាសត្វត្រចៀកកាំ និង៣ច្បាប់សម្រាប់ការថែរក្សាសត្វព្រៃប្រភេទផ្សេងទៀតមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកោះកុង កំពត បាត់ដំបង ពោធិ៍សាត់ រតនគិរី កំពង់ចាម សៀមរាប កណ្តាល និងខេត្តបន្ទាយមានជ័យ

- បានចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃក្នុងស្រុកចំនួន ៩សន្លឹកមានស្វាក្តាមចំនួន ៣ ០៥០ក្បាល និងសត្វប្រវឹកចំនួន ៧៣៦ក្បាល និងលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃសម្រាប់នាំចេញទៅក្រៅប្រទេសចំនួន ១៧សន្លឹក (ពន្យារចំនួន ៣សន្លឹក) មានសត្វស្វាក្តាមចំនួន ៧ ០១៨ក្បាល។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន ៧មានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញចំនួន ៨ទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តសៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តកំពង់ធំចំនួន ២ទីតាំងមានសត្វស្វាក្តាមសរុបចំនួន ៦៥ ៩០០ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ៣ ៦២០ក្បាល ដឹកជញ្ជូនក្នុងស្រុកចំនួន ៣ ០៥០ក្បាល និងដឹកជញ្ជូនឆ្ពោះទៅកាន់មាត់ច្រកទ្វារអន្តរជាតិសម្រាប់នាំចេញទៅក្រៅប្រទេសចំនួន ៦ ៦៥៨ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៨៩៦ក្បាល (បក្សីចំនួន ៥៦ប្រភេទ ថនិកសត្វចំនួន ៤៦ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ១ ០៣៧ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ១៧៩ក្បាល ស្តារលទ្ធភាពជីវសាស្រ្តសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន ៥៥៥ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI បានល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥ គឺ អារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- បានរកឃើញសំបុកក្រពើភ្នំ ១សំបុកមានពងចំនួន ២២គ្រាប់នៅបឹងវាលវែង អូរសោម ខេត្តពោធិ៍សាត់ និងស្រាវជ្រាវវត្តមានក្រពើភ្នំនៅក្នុងខេត្តស្ទឹងត្រែងដោយរកឃើញស្នាមជើងក្រពើភ្នំចំនួន ៣កន្លែង

- បានជួសជុលផ្លូវដោយក្រាលគ្រួសក្រហមសរុបប្រវែង ៧,៨០គីឡូម៉ែត្រ និងកាប់ឆ្ការអនាម័យព្រៃទំហំ ១៧,៥២ហ.ត នៅក្នុងតំបន់សួនសត្វ។

### ៣.៤ ការងារដាំដើមឈើ

- បាននិងកំពុងថែទាំប្រឡាយប្រវែង ១៨ ០០០ម៉ែត្រ ក្នុងនោះប្រឡាយជីកឆ្នាំ២០១៨ ប្រវែង ១០ ០០០ម៉ែត្រ និងឆ្នាំ២០១៩ មានប្រវែង ៨ ០០០ម៉ែត្រ ស្ថិតនៅខេត្តកំពង់ធំ និងខេត្តព្រះសីហនុ និងគម្រោង ជីកប្រឡាយការពារចម្ការឈើគ្រញូងនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្ម ខេត្តកំពង់ធំប្រចាំឆ្នាំ២០២០ សម្រេចបានប្រវែង ៣ ៦០០ ម៉ែត្រ

- បាននិងកំពុងថែទាំចម្ការឈើសរុប ៩៣២ហ.ត ក្នុងនោះចម្ការពូជឈើ ៨៩ហ.ត ឡូត៍បង្ហាញកសិ-រុក្ខកម្មទំហំ ៤៩ហ.ត ចម្ការឈើដាំទំហំ ៧៥៤ហ.ត និងចម្ការរុក្ខទិវា ០៩ កក្កដាទំហំ ៤០ហ.ត ស្ថិតក្នុងខេត្តកំពត កណ្តាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ

- បានបណ្តុះកូនឈើគ្រប់ប្រភេទចំនួន ៨៤៥ ៨៥៥ដើម ក្នុងនោះថ្នាលបណ្តុះកូនឈើតាមបណ្តាខណ្ឌរដ្ឋបាលព្រៃឈើនៅទូទាំងប្រទេសចំនួន ២៨៤ ០១៥ដើម និងថ្នាលបណ្តុះកូនឈើចំនួន ៦កន្លែងក្នុងខេត្តចំនួន ៥រួមមានៈ ខេត្តពោធិ៍សាត់ កំពង់ធំ តាកែវ កំពង់ចាម និងខេត្តកណ្តាល ២កន្លែងសរុបចំនួន ១៥៦ ៨៤០ដើម។

### ៣.៥ ការងារនីតិកម្មនិងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ៨០៧ករណី ដោយពិន័យអន្តរការណ៍ចំនួន ៣១៦ករណី និងបញ្ជូនទៅតុលាការចំនួន ៤៩១ករណី

- ចំពោះវត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមានឈើមូល-ជ្រុងសរុបចំនួន ៦១ម៣ ឈើអារចំនួន ១ ៦៥៦ម៣ (ចំនួន ៧៣៣ករណី) ផ្ទៃដីព្រៃឈើកាប់រានមានទំហំ ៧៧២ហ.ត មានចំនួន ៤៧ករណី គឺខេត្តស្ទឹងត្រែងចំនួន ៤ករណី ក្រចេះចំនួន ១៣ករណី សៀមរាបចំនួន ៨ករណី កំពង់ស្ពឺចំនួន ២ករណី ព្រះសីហនុចំនួន ៤ករណី កំពង់ឆ្នាំងចំនួន ៨ករណី រតនគិរីចំនួន ២ករណី បន្ទាយមានជ័យចំនួន ១ករណី និងខេត្តព្រះវិហារចំនួន ៥ករណី។ វត្ថុតាងសត្វព្រៃបានចាប់ឃាត់ចំនួន ១ ២៧៦ក្បាល និង៨៦០គ.ក្រ មានចំនួន ២៦ករណី គឺក្រុមអន្តរាគមន៍

បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើចំនួន ២០ករណី ខណ្ឌរដ្ឋបាលព្រៃឈើខេត្តរតនគិរីចំនួន ៣ករណី កោះកុងចំនួន ១ករណី ក្រចេះចំនួន ១ករណី និងខណ្ឌរដ្ឋបាលព្រៃឈើខេត្តកំពង់ស្ពឺចំនួន ១ករណី និងអនុផលព្រៃឈើព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត។

**៣.៦ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម**

- បានបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន ១១រាជធានី-ខេត្ត គឺរាជធានីភ្នំពេញ ខេត្តតាកែវ ស្វាយរៀង រតនគិរី ព្រៃវែង កំពង់ធំ កណ្តាល កំពង់ស្ពឺ កំពង់ចាម ត្បូងឃ្មុំ និងខេត្តសៀមរាប ស្មើនឹង១៤កន្លែង

- បានបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើ និងឡធ្យូងចំនួន ៨កន្លែង និងពន្យារសុពលភាពរោងម៉ាស៊ីនអារ កែច្នៃឈើចំនួន ៩កន្លែង

- ក្រុមហ៊ុនចំនួន ៦បាននាំចេញផលិតផលភានទេវតា ឈើកែច្នៃ និងជ័រទឹកទៅក្រៅប្រទេសចំនួន ១ ១១៤ម៣ និងជ័រទឹកចំនួន ២២០តោន

- ក្រុមហ៊ុនចំនួន ៤បាននាំចូលឈើកែច្នៃមានបរិមាណចំនួន ១ ២១១ម៣

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន ៨មានបរិមាណឈើកែច្នៃសរុបចំនួន ១ ៥០៦ម៣ប្រេងខ្យល់កាត់ជាកង់ៗចំនួន ១ ៥០០ស្ទេរ និងជ័រទឹកចំនួន ២៦៤តោន

- បានផ្តល់ទិដ្ឋការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន ៥មានបរិមាណឈើកែច្នៃ (MDF, Wood Panel, Dark Red Meranti, Doussie, Chanfuta) សរុបចំនួន ១ ៦៩៥ម៣ ។

**៣.៧ ការងារចំណូលព្រៃឈើ**

- បានចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើចំនួន ៨ ៤១២ ២១៧ ៤៧០រៀល និង៤០៦ ៥៤៧,៥៩ ដុល្លារ។

## ៤ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្មូនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យ និងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

**៤.២ ការងារសុខភាពសត្វ**

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** បទល្មើសសត្វនិងផលិត-ផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ១២២ករណី និងរាជធានី-ខេត្តចំនួន ២៥ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ៨២ ៥៤៩លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។
- **ការងារផ្សព្វផ្សាយបច្ចេកទេស៖** ប្រជុំណែនាំបច្ចេកទេសចិញ្ចឹមសត្វ និងជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន ៤ខេត្ត ប្រជុំណែនាំពីជំងឺផ្តាសាយបក្សីជាមួយកសិករនិងអ្នកពាក់ព័ន្ធនៅតាមបណ្តាខេត្តចំនួន ១០ខេត្ត បណ្តុះបណ្តាលវិធីសាស្ត្រផ្សព្វផ្សាយ និងការបង្កើតសម្ភារផ្សព្វផ្សាយនៅខេត្តចំនួន ១ខេត្ត។
- **ការងារនីតិកម្ម និងវិវាទ**

- បានប្រកាសស្តីពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត និងកំណត់ការគ្រប់គ្រងចំណីសត្វ វត្ថុធាតុដើម ឬសារធាតុបន្ថែមដែលធ្វើពាណិជ្ជកម្ម ការផលិត និងធ្វើការលាយផ្សំបានចូលជាធរមាន

- បានរៀបចំប្រកាសស្តីពីនីតិវិធី និងសិទ្ធិពិន័យអន្តរការណ៍លើបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ និងបាននិងកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀត។

### ៤.៣ ការងារស្រាវជ្រាវ

- ការងារស្រាវជ្រាវផលិតកម្ម៖ បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៦ក្បាល។ ចំណែកស្ថានីយចិញ្ចឹមជ្រូកពូជបង្កាត់កម្ពុជា-ចិន មានជ្រូកសរុបចំនួន ១២២ក្បាល (គិតត្រឹមខែមីនា ឆ្នាំ២០២០)។ ចាប់ពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០ ស្ថានីយចិញ្ចឹមជ្រូកពូជបង្កាត់កម្ពុជា-ចិន ពុំមានជ្រូកទៀតទេ ហើយត្រូវបានបិទទាំងស្រុង ដោយសារមានការឆ្លងរាលដាលនៃជំងឺប៉េស្តជ្រូកអាហ្វ្រិក។
- ការងារស្រាវជ្រាវបសុព្យាបាលៈ ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ៨ ៣៥០វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។

## ៥ ផ្នែកជលផល

### ៥.១ វារីវប្បកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីបានបញ្ចប់ត្រឹមចំនួន ១ ៥០០តោន ស្មើនឹង១២,៥០% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០១៩ ថយចុះចំនួន ៨៧០តោន

- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ១៣២ ៩៥០តោន ស្មើនឹង៣៨,៥៤% នៃផែនការចំនួន ៣៤៥ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០១៩ ថយចុះចំនួន ៥៥០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ៣០ ៧៨០តោន ស្មើនឹង២១,២៣% នៃផែនការចំនួន ១៤៥ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០១៩ ថយចុះចំនួន ១ ៣០០តោន។

#### ៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ៥៧ ១៦០តោន ស្មើនឹង៥១,៩៦% នៃផែនការចំនួន ១១០ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០១៩ ថយចុះចំនួន ៦៤០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ១៣៥ ៤១៥តោន ស្មើនឹង៣៧,៦២% នៃផែនការចំនួន ៣៦០ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០១៩ កើនឡើងចំនួន ២២ ៥៦៩តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ១៤២ ២៤០ក្បាល ស្មើនឹង៤៧,៤១% នៃផែនការចំនួន ៣០០ ០០០ក្បាល ប្រៀបធៀបឆមាសទី១ ឆ្នាំ២០១៩ កើនឡើងចំនួន ៨៤០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ៨៣ ៥០០០ ០០០កូន ស្មើនឹង៣៤,៧៩% នៃផែនការចំនួន ២៤០ ០០០ ០០០កូន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០១៩ កើនឡើងចំនួនប្រមាណ ៥០០ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ២៧ ២៥០តោន ស្មើនឹង៣៣,២៣% នៃផែនការចំនួន ៨២ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០១៩ ថយចុះចំនួន ៦០០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ៦ ១១០តោន ស្មើនឹង៦៧,៨៩% នៃផែនការចំនួន ៩ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០១៩ កើនឡើងចំនួន ៩០តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៣៥ ៩១២ ០០០លីត្រ ស្មើនឹង៦៥,២៩% នៃផែនការចំនួន ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបឆមាសទី១ ឆ្នាំ២០១៩ ថយចុះចំនួន ៦៨៨ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ១ ១៩៦ករណី ប្រៀបធៀបឆមាសទី១ ឆ្នាំ២០១៩ ថយចុះចំនួន ១២៥ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ១ ០៩៤ករណី និងសមុទ្រចំនួន ១០២ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញចំនួន ១ ១៤០តោន ស្មើនឹង៧,៦០% នៃផែនការចំនួន ១៥ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០១៩ ថយចុះចំនួន ៤ ៣២០តោន

- ផលនេសាទកែច្នៃនាំចេញចំនួន ២៣២តោន ស្មើនឹង៤,៦៤% នៃផែនការចំនួន ៥ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០១៩ ថយចុះចំនួន ៣ ០១៨តោន។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលបានចំនួន ៣៤១ ៤៨៤ ៣៦០រៀល ស្មើនឹង១១,៤១% នៃផែនការចំនួន ២ ៩៩៤ ០០០ ០០០រៀល ប្រៀបធៀបឆមាសទី១ឆ្នាំ២០១៩ ថយចុះចំនួន ៣៣ ៨៩៤ ៥១២រៀល។

## ៦ ផ្នែកអធិការដ្ឋាន

- បានចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
- បានចូលរួមជួបពិភាក្សាការងារជាមួយឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបងលើការងារដឹកនាំរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង
- បានចុះធ្វើអធិការកិច្ចលើការងារដឹកនាំ គ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង និងពិនិត្យចំណុចខ្វះខាតមួយចំនួនរបស់មន្ទីរដែលក្រសួងបានណែនាំឱ្យកែលម្អកន្លងមក
- បានចូលរួមជួបពិភាក្សាការងារជាមួយឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តតាកែវ និងថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវពាក់ព័ន្ធការងារដឹកនាំ និងគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវ
- បានចូលរួមជួបពិភាក្សាការងារជាមួយឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តព្រៃវែង និងថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រៃវែង
- បានអញ្ជើញថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តប៉ៃលិនធ្វើការណែនាំ និងជំរុញឱ្យអនុវត្តកែលម្អចំណុចខ្វះខាតរបស់មន្ទីរដែលក្រសួងចេញលិខិតឱ្យកែលម្អកន្លងមក
- បានចុះពិនិត្យ និងប្រជុំពិភាក្សាជាមួយឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងសមត្ថកិច្ចពាក់ព័ន្ធពីបញ្ហាគ្រប់គ្រងវិស័យជលផល និងព្រៃកោងកាងនៅខេត្តកែប
- បានចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងរបស់ខណ្ឌរដ្ឋបាលព្រៃឈើឧត្តរមានជ័យនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តឧត្តរមានជ័យ
- បានចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តរតនគិរី និងមណ្ឌលគិរី និងជំរុញឱ្យអនុវត្តកែលម្អចំណុចខ្វះខាតរបស់មន្ទីរដែលក្រសួងចេញលិខិតឱ្យកែលម្អកន្លងមក
- បានទទួលពាក្យបណ្ដឹងចំនួន ២ករណី
- បានស្រាវជ្រាវព័ត៌មានតាមបណ្ដាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ២៦៣ករណី
- បានចូលរួមកម្មវិធីប្រជុំ សិក្ខាសាលា និងការងារសង្គមចំនួន ៥៦លើក។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៤ ៣៥៧ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ១ ៧៨៥ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ១ ៦៩៤ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ៨៧៨ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល
- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៥ ៦៥៨ច្បាប់ ចេញប្រកាស សេចក្ដីសម្រេច និងសារាចរចំនួន ២៦២ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ៩៨ច្បាប់
- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្ដាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្ដាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៥ ៨៧៩នាក់ (ស្រី១ ៤២៧នាក់) ស្មើនឹង២៤,២៧% រួមមាន៖
  + អង្គភាពថ្នាក់កណ្ដាលចំនួន ២ ៩២៧នាក់ (ស្រី៨២៤នាក់) ស្មើនឹង២៨,១៥%

+ អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩៥២នាក់ (ស្រី៦០៣នាក់) ស្មើនឹង២០,៤២%

- បានតែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន៦៧នាក់ (ស្រី១៦នាក់)
- បានរៀបចំប្រកាសលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌចំនួន ១៧នាក់ (ស្រី៤នាក់)
- បានរៀបចំប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន ៨នាក់ និងផ្ទេរចូលក្នុងក្រសួងចំនួន ៦នាក់ (ស្រី៣នាក់)
- បានរៀបចំលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារចំនួន ៤៨នាក់ (ស្រី៣៣នាក់) ក្នុងនោះ៖ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន ២៦នាក់(ស្រី១២នាក់) ច្បាប់ឈប់សម្រាកព្យាបាលជំងឺចំនួន ១នាក់ ច្បាប់ឈប់សម្រាករយៈពេលខ្លីចំនួន ២នាក់ ច្បាប់ឈប់សម្រាកមានធុរៈផ្ទាល់ខ្លួនចំនួន ២នាក់ និងច្បាប់ឈប់សម្រាកលំហែមាតុភាពចំនួន ១៧នាក់
- បានរៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន ២២នាក់ (ស្រី២នាក់)
- បានរៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យចូលបម្រើការងារវិញចំនួន ១៤នាក់
- បានរៀបចំប្រកាសស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ចំនួន ២៣នាក់ (ស្រី១៣នាក់)
- បានរៀបចំប្រកាសស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍មុនអាយុចំនួន ២៦នាក់ (ស្រី៣នាក់)
- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ១ ១៣១នាក់ (ស្រី២៥៨នាក់) ក្នុងនោះ៖
  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ៩៧៣នាក់ (ស្រី២១៤នាក់)
  + ការបណ្តុះបណ្តាលក្រៅប្រទេសសរុបចំនួន ១៥៨នាក់ (ស្រី៤៤នាក់)។

## ៩ ផ្នែកផែនការ និងស្ថិតិ

- បានរៀបចំសិក្ខាសាលាស្តីពីយន្តការ នីតិវិធី សម្រាប់រៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ (កវស) ៣ឆ្នាំរំកិល ឆ្នាំ២០២១-២០២៣ នៅខេត្តតាកែវ និងបានបំពេញគម្រោងកម្មវិធីវិនិយោគសាធារណៈ (កវស) ៣ឆ្នាំរំកិលនេះទៅក្នុងប្រព័ន្ធរបស់ក្រសួងផែនការ និងបញ្ជូនគម្រោងកម្មវិធីវិនិយោគសាធារណៈ (កវស) ៣ឆ្នាំរំកិលឆ្នាំ២០២១-២០២៣ ជូនទៅក្រសួងផែនការ
- បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការរៀបចំផែនការមេវិស័យកសិកម្មឆ្នាំ២០៣០
- បានចូលរួមចុះសម្របសម្រួល និងដឹកនាំការប្រមូលទិន្នន័យលើការសិក្សាខ្សែច្រវាក់តម្លៃផលិតផលកសិកម្មដើម្បីជំរុញទីផ្សារប្រកបដោយបរិយាប័ន្នសម្រាប់កសិករ ខ្នាតតូច នៅខេត្តបាត់ដំបង កំពង់ធំ សៀមរាប បន្ទាយមានជ័យ មណ្ឌលគិរី រតនគិរី កែប កំពត កោះកុង ព្រះសីហនុ ព្រះវិហារ កណ្តាល កំពង់ចាម ស្វាយរៀង តាកែវ និងខេត្តកំពង់ស្ពឺ
- បានអនុញ្ញាតជាគោលការណ៍ឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ឆ្នាំងបញ្ចេញស្រូវពូជចាស់អន់គុណភាពចំនួន ១០ ៦៣៣គ.ក្រ
- បានរៀបចំប្រមូលផ្តុំឯកសារវិនិយោគសម្បទានដីសេដ្ឋកិច្ចតាមបណ្តាក្រុមហ៊ុនដើម្បីថែរក្សាទុក
- បានចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃចន្ទ ពុធ និងសុក្រ តម្លៃលក់រាយម្តងក្នុងសប្តាហ៍នូវរៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានី-ខេត្តទាំង២៥
- បន្តការផ្សព្វផ្សាយតម្លៃទីផ្សារកសិកម្មតាមព្រឹត្តិបត្រព័ត៌មានទីផ្សារកសិកម្មតាមប្រព័ន្ធតាម SMS និងគេហទំព័រ www.Agriculturalmarkintinformation.org.kh
- បានចុះប្រមូលទិន្នន័យ និងវាយតម្លៃទៅលើស្ថានភាពដែលជាសក្តានុពលនៃផលិតភាពកសិកម្ម ព្រមទាំងកំណត់សហគមន៍គោលដៅដើម្បីជំរុញការអនុវត្តវិធានការឆ្លើយតបជាបន្ទាន់ក្នុងដំណាក់កាលនៃការរីករាលដាលជំងឺកូវីត-១៩
- បានចូលរួមចុះពិនិត្យ តាមដាន និងវាយតម្លៃវឌ្ឍនភាពរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៩ បានចំនួន ៥លើក ស្មើនឹង ៥ខេត្ត គឺខេត្តមណ្ឌលគិរី ត្បូងឃ្មុំ ស្ទឹងត្រែង ស្វាយរៀង និងខេត្តកំពង់ចាម
- បានរៀបចំពង្រាងបញ្ជីសំនួរ និងបញ្ជីត្រួតពិនិត្យការងារសម្រាប់សកម្មភាពត្រួតពិនិត្យ និងតាមដានផលប៉ះពាល់បរិស្ថាននៅទីសត្តឃាតដ្ឋាន។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- បានអនុវត្តប្រមូលចំណូលនូវទឹកប្រាក់សរុបចំនួន ៤ ៨៤៩ ៣០៨ ៦៥១រៀល
- អង្គភាពប្រមូលចំណូលទាំង៦បានចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធNRMIS សរុបចំនួន ៤ ៧០០ ៣៥០ ៥១១រៀល
- បានបញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបមានចំនួន ៦ ៤២៧ ៩៦៩ ៤៤១រៀល

- បានចូលរួមចុះពិនិត្យមើលស្ថានភាពសហគមន៍ដាំបន្លែនៅខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ
- បានចូលរួមប្រជុំពិភាក្សាលើសកម្មភាពការងារប្រមូលចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចបង់ចូលថវិការដ្ឋសម្រាប់ឆ្នាំ២០២០
- បានរៀបចំលិខិតសំណើសុំថវិកាចំនួន ២០៦ ៨០៦,១៨ដុល្លារ ដើម្បីបំពេញឡើងវិញចូលគណនីគម្រោងរបៀងអភិរក្សជីវចម្រុះមហាអនុតំបន់មេគង្គ
- បានរៀបចំលិខិតជូនដំណឹងស្តីពីកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនក្រុមហ៊ុនចំនួន ២១ក្រុមហ៊ុន
- បានចុះពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីគណនេយ្យឆ្នាំ២០១៩ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកោះកុង
- បានរៀបចំឯកសារដេញថ្លៃការងារជួសជុលកាណូត អូប៉័រ និងនាវាដែកប្រចាំឆ្នាំ២០២០ របស់រដ្ឋបាលជលផល
- បានបើកសំណើដេញថ្លៃ និងរៀបចំឯកសារកិច្ចសន្យាការផ្គត់ផ្គង់សម្ភារបរិក្ខារបសុពេទ្យឆ្នាំ២០២០ របស់អគ្គ-នាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ ផែនការថវិកាឆ្នាំ២០២១ ផែនការលទ្ធកម្មសាធារណៈឆ្នាំ២០២១ និងផែនការរដ្ឋទេយ្យបុរេប្រទានឆ្នាំ២០២១
- បានរៀបចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់ M1 ប្រចាំត្រីមាស និងរបាយ-ការណ៍សមិទ្ធកម្មប្រចាំឆមាសទី១
- បានចុះធ្វើសវនកម្មតាមផែនការសកម្មភាពសវនកម្មសវនកម្មផ្ទៃបានចំនួន ១៨សវនដ្ឋាន ស្មើនឹង៣៤,៦១% នៃផែនការចំនួន ៥២សវនដ្ឋាន ដោយរកឃើញលទ្ធផលសវនកម្ម និងផ្តល់អនុសាសន៍សម្រាប់សវនដ្ឋានកែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងចំនួន ៩១អនុសាសន៍ និងការអនុវត្តអនុសាសន៍គ្រាមុនរបស់សវនដ្ឋានសម្រេចបានចំនួន ៥៧,៣៥% នៃផែនការចំនួន៥២%។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានទទួលជួបភ្ញៀវស្ថានទូតចំនួន ១លើក និងវិស័យឯកជនចំនួន ១លើក
- បានចូលរួមកិច្ចប្រជុំចំនួន ៦លើក សិក្ខាសាលាចំនួន ១លើក ទស្សនកិច្ចសិក្សាចំនួន ១លើក និងសន្និសីទចំនួន ១លើកក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី និងកិច្ចប្រជុំចំនួន ១លើកក្រោមក្របខ័ណ្ឌអាស៊ាន
- ការងារក្រៅប្រទេសបានចូលរួមសិក្ខាសាលាចំនួន ៥លើក និងវគ្គបណ្តុះបណ្តាលចំនួន ១០លើកក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី និងសិក្ខាសាលាចំនួន ៥លើក និងវគ្គបណ្តុះបណ្តាលចំនួន ១លើកក្រោមក្របខ័ណ្ឌអាស៊ាន
- បានសម្របសម្រួលរៀបចំកិច្ចប្រជុំ និងវគ្គបណ្តុះបណ្តាលនៅក្នុងប្រទេសចំនួន ១៤លើក។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១២៥ក្រុមហ៊ុន សរុបចំនួន ១ ៤៤០មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៣៥ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៤៣ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៣៨ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតលាយផ្សំ ឬវេចខ្ចប់ជាថ្មីថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៧ក្រុមហ៊ុន។

### ១៣.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៤០ក្រុមហ៊ុន សរុបចំនួន ២៩៣សំណាក។

### ១៣.៣ ការងារអធិការកិច្ចបទដ្ឋានគតិយុត្ត

- បានពិនិត្យសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត និងការកំណត់ការគ្រប់គ្រងចំណីសត្វ វត្ថុ-ធាតុដើម ឬសារធាតុបន្ថែមដែលធ្វើពាណិជ្ជកម្ម ការផលិត និងការលាយផ្សំ
- បានប្រជុំពិនិត្យលើខ្លឹមសារកែសម្រួលលើសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគោលការណ៍ណែនាំវិធានសុវត្ថិភាពក្នុងការប្រើប្រាស់ថ្នាំកសិកម្ម ការបោះសំណល់ពីការប្រើប្រាស់ថ្នាំកសិកម្ម និងសំបកវេចខ្ចប់ថ្នាំកសិកម្ម។

## ១៣.៤ ការងារអនុវត្តច្បាប់

- បានចុះត្រួតពិនិត្យការនាំចូលថ្នាំកសិកម្ម និងជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយរបស់ក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៧៣ក្រុមហ៊ុន

- បានចុះធ្វើអធិការកិច្ចត្រួតពិនិត្យបទល្មើសថ្នាំកសិកម្ម និងជីកសិកម្មតាមខេត្តគោលដៅចំនួន ៥ខេត្ត ស្មើនឹង ៨លើក គឺខេត្តសៀមរាប បន្ទាយមានជ័យ ប៉ៃលិន បាត់ដំបង និងខេត្តកណ្តាលលើ៥៥ដេប៉ូ ៤ទីតាំងឃ្លាំងសន្និធិ និង ១មធ្យោបាយដឹកជញ្ជូន ៨ក្រុមហ៊ុន និងសម្រេចពិន័យអន្តរការណ៍ចំនួន ១៥ករណី

- បានធ្វើការសម្រេចពិន័យអន្តរការណ៍ចំពោះក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មដែលខកខានពុំបានប្រកាសប្រតិវេទន៍ស្តីពីការនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៥ក្រុមហ៊ុន ស្មើនឹង៥ករណី។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- បានថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងសរុបចំនួន ១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

- បានបង្កើត និងដាក់ឱ្យដំណើរការកម្មវិធីទូរសព្ទដៃឆ្លាតវៃ (Android Mobile App) ដែលមានឈ្មោះថា AgriLibrary របស់បណ្ណាល័យកសិកម្ម

- បានតាមដានទិន្នន័យ និងសម្អាត Catch នៅលើ Cloud Server នៃគេហទំព័រទាំង៤១ (ក្រសួង អគ្គនាយក នាយកដ្ឋាន និងមន្ទីររាជធានី-ខេត្ត)

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ និងចុះបណ្តុះបណ្តាលតាមដានការប្រើប្រាស់ និងបង្ហាញមុខងារប្រើប្រាស់ថ្មីៗលើគេហទំព័ររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ៦ដូចជា ខេត្តសៀមរាប កំពង់ធំ កំពង់ស្ពឺ កោះកុង តាកែវ និងខេត្តព្រះសីហនុ

- បានចុះប្រមូលទីតាំងដំណាំស្រូវប្រាំងចំនួន ៣ខេត្ត គឺខេត្តស្វាយរៀង តាកែវ និងខេត្តព្រៃវែង ដើម្បីរៀបចំផែនទីដំណាំកសិកម្មសម្រាប់បញ្ចូលក្នុងគេហទំព័រព័ត៌មានភូមិសាស្ត្រកសិកម្ម

- បន្តការធ្វើបច្ចុប្បន្នភាពលើគេហទំព័របណ្ណាល័យកសិកម្ម និងជំរុញការផ្សព្វផ្សាយ និងបណ្តុះបណ្តាលការប្រើ-ប្រាស់អំពីគេហទំព័របណ្ណាល័យកសិកម្ម និងពិនិត្យអំពីការរៀបចំបណ្ណាល័យរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ៥ដូចជា ខេត្តព្រះវិហារ ក្រចេះ សៀមរាប កណ្តាល និងខេត្តស្វាយរៀង។

## ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានរៀបចំវគ្គបណ្តុះបណ្តាល និងរៀបចំផែនការប្រមូលទិន្នន័យទី២សម្រាប់សិក្សាវិភាគប្រព័ន្ធកសិកម្មនៅខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ដែលមានអ្នកចូលរួមចំនួន ៤២នាក់

- បានរៀបចំធ្វើជាទម្រង់លក់កសិផល ទម្រង់ប្រមូលទិញកសិផលរបស់កសិករ អាជីវករតាមបណ្តារាជធានី-ខេត្តសម្រាប់ជួយរកទីផ្សារក្នុងការលក់ផលិតផលកសិកម្មរបស់កសិករ និងទម្រង់ជាបច្ចេកទេសក្នុងការដាំដំណាំ ចិញ្ចឹមត្រី និង ចិញ្ចឹមសត្វ

- បានចុះទៅថត Video បទយកការណ៍ចំនួន ១១ប្រធានបទ រួមមាន ដំណាំបន្លែគ្រីន បេ ប៊ីលីស ដំណាំទំពាំង-ផ្អែម ការចិញ្ចឹមមាន់ភ្នាស់យកកូនលក់ ការដាំដុះបន្លែប្រើប្រើប្រាស់ប្រព័ន្ធដំណក់ទឹក ភាពជោគជ័យរបស់កសិករក្នុងការដាំដុះបន្លែតាមបច្ចេកទេសកសិកម្មធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ការចងក្រងបណ្តុំបន្លែសុវត្ថិភាពភ្ជាប់ទៅនឹងទីផ្សារខេត្តកណ្តាល ដំណាំការ៉ុត ដំណាំស្ពៃក្តោប ដំណាំត្រសក់ចំណារនៅខេត្តក្រចេះ និងដំណាំរុក្ខជាតិលម្អនៅខេត្តកណ្តាល

- បានផលិតឯកសារ Video នាទីចុះស្រែជាមួយកសិករបានចំនួន ៨រួមមាន បច្ចេកទេសចិញ្ចឹមមាន់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការដាំដំណាំបន្លែបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ បណ្តុំកសិករដាំដំណាំខ្ទឹមស្លឹកនៅខេត្តកំពង់ស្ពឺ ដំណាំបន្លែផ្ទះសំណាញ់ ការចិញ្ចឹមសត្វនៅខេត្តតាកែវ ផលិតកម្មដំណាំបន្លែប្រើប្រព័ន្ធដំណក់ទឹក និងការចិញ្ចឹមគោបំប៉ន

- បានបញ្ចូលអត្ថបទបច្ចេកទេសកសិកម្មចំនួន ៣១ដើម្បីចាក់ផ្សាយតាមវិទ្យុរួមមានអត្ថបទ ពូជស្រូវ បច្ចេកទេសដាំបន្លែ បច្ចេកទេសការចិញ្ចឹមអន្ទង់ក្នុងអាងប្លាស្ទិក បច្ចេកទេសការចិញ្ចឹមគោនិងបំប៉នគោ វិធានជីវសុវត្ថិភាពលើបច្ចេក-ទេសការចិញ្ចឹមបក្សីជាលក្ខណៈគ្រួសារ បច្ចេកទេសដាំដំណាំពោត ម្នាស់ ក្រូចពោធិ៍សាត់ធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងបច្ចេកទេសការចិញ្ចឹមកង្កែបក្នុងអាង

- បានផ្សព្វផ្សាយកសិកម្មតាមប្រព័ន្ធសេវាព័ត៌មានវិទ្យាស្ដីពីឯកសារបច្ចេកទេសកសិកម្មចំនួន ១២១អត្ថបទ អ្នកទាញយកឯកសារផ្សេងៗពីគេហទំព័រចំនួន ៦៥ ៧៧៩ដង និងអ្នកចូលមើលចំនួន ២៩៩ ៧៧៥នាក់។

## ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- បានចុះសិក្សាពីសក្ដានុពលដំណាំបន្លែផ្លែឈើ ជាពិសេសបន្លែសរីរាង្គ និងការវិភាគគុណភាពទឹកក្រោមដីសម្រាប់ស្រោចស្រពប្រើប្រាស់ និងផ្សព្វផ្សាយពីផលប្រយោជន៍នៃការផលិតមានផែនការដើម្បីឆ្លើយតបតម្រូវការទីផ្សារតាមយន្ត-ការកិច្ចសន្យាផលិតកម្មកសិកម្ម

- បានសហការជាមួយក្រុមហ៊ុន Top Planning Japan លើការសិក្សាខ្សែច្រវ៉ាក់តម្លៃស្វាយចន្ទីកម្ពុជា លើខេត្តគោលដៅចំនួន ៤ខេត្ត គឺ ខេត្តកំពង់ធំ កំពង់ចាម សៀមរាប និងខេត្តព្រះវិហារ និងសិក្សាគម្រោងសាកល្បងជាមួយសិប្បកម្មកែច្នៃគ្រាប់ស្វាយចន្ទីជ័យសំបូរ ខេត្តកំពង់ធំ

- បានចុះកិច្ចសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្មរវាងកសិករ និងសហគមន៍កសិកម្មកម្ពុជាលើកិច្ចសន្យាដាំដុះចំបក់បារាំង (Macadamia) នឹងស្លឹកគ្រៃក្រអូប

- បានចុះពិនិត្យ និងវាយតម្លៃពីវឌ្ឍនភាពនៃការអភិវឌ្ឍដំណាំសូត្ររបស់ក្រុមហ៊ុនឆាយណាហ្រ្គេតខស ស្ថិតនៅក្នុងស្រុករវៀង ខេត្តព្រះវិហារ

- បាននិងកំពុងសម្របសម្រួល និងចងក្រងទិន្នន័យសហគ្រាសកែច្នៃផលិតផលកសិកម្មនៅកម្ពុជា

- បានចុះសិក្សា និងប្រមូលទិន្នន័យបឋមអំពីខ្សែច្រវ៉ាក់តម្លៃផលិតផលម្រេចនៅខេត្តព្រះវិហារ

- បានសហប្រតិបត្តិការជាមួយក្រុមហ៊ុន Top Planning Japan ក្រោមជំនួយគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) លើគម្រោងគំរូអាជីវកម្មស្របតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDGs) ជាមួយវិស័យឯកជនដើម្បីបង្កើតខ្សែច្រវ៉ាក់តម្លៃ និងធានាតម្លៃបន្ថែមខ្ពស់សម្រាប់គ្រាប់ស្វាយចន្ទីនៅកម្ពុជា

- បានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីវិធីសាស្ត្រថ្មីៗ នៃការវិភាគគុណភាព សុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហារនៅមន្ទីរពិសោធន៍ផលិតផលកសិកម្ម និងចំណីអាហារកម្ពុជា

- បានចុះបណ្ដុះបណ្ដាលកសិករស្ដីពីបច្ចេកទេសក្រោយប្រមូលផលនៃផលិតផលកសិកម្មនៅខេត្តស្ទឹងត្រែង

- បានចុះបណ្ដុះបណ្ដាលកសិករស្ដីពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិនៅខេត្តកំពត

- បានចុះបណ្ដុះបណ្ដាលកសិករស្ដីពីការលើកកម្ពស់ស្តង់ដារ គុណភាព និងសុវត្ថិភាពនៃផលិតកម្មកសិកម្មនៅខេត្តកំពង់ធំ

- បានកសាងគម្រោងវិភាគកាកសំណល់គីមី ថ្នាំកសិកម្ម លោហៈធ្ងន់ មីក្រូតុកស៊ីន និងសារធាតុពុលផ្សេងៗទៀតក្នុងផលិតផលកសិកម្ម និងចំណីអាហារ

- បានវិភាគរកសមាសធាតុគីមី លោហៈធ្ងន់ គុណភាព និងអាហាររូបត្ថម្ភនៅក្នុងផលិផលកសិកម្ម (ម្សៅអង្ករពោតលឿង ទឹកឃ្មុំ បន្លែស្រស់)

- បានវិភាគរកសមាសធាតុ អាស៊ូត ផូស្វ័រ និងប៉ូតាស្យូមនៅក្នុងជីលាមកសត្វ ជីកាកឡ ទឹកស្ងោរគ្រាប់ស្វាយចន្ទីកាកសំណល់ផ្ទះបាយ។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្ដុះបណ្ដាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានបន្តការអភិរក្សពូជដំណាំចំនួន ៣៨ប្រភេទ រួមមានស្រូវចំនួន ៦ ៧៧៦បញ្ជិក/សំណាក និងដំណាំផ្សេងៗចំនួន ៣៧ប្រភេទ សរុបចំនួន ២ ៣៤០បញ្ជីក/សំណាក សរុបទាំងអស់ចំនួន ៩ ១១៦បញ្ជីក/សំណាក

- បានដាំវាយតម្លៃប្រភេទពូជម្ទេស និងត្រសក់ស្រូវដែលទើបប្រមូលចំនួន ៩០ពូជ និងកំពុងពិនិត្យបង្កើយសៀវភៅកាតាឡុកម្ទេសទី១សម្រាប់បោះពុម្ពនាពេលខាងក្រោយ

- បានធ្វើពិសោធចំនួន ៤២ប្រភេទនៅ២១៧កន្លែង ក្នុងនោះ ពិសោធន៍បន្សាំពូជលើស្រែកសិករ និងស្រែបង្ហាញចំនួន ១២២កន្លែង ធ្វើទិវាស្រែបង្ហាញចំនួន ១១លើក មានកសិករចូលរួមចំនួន ៨៤១នាក់ (ស្រី២១៨នាក់) និងបើកវគ្គបណ្ដុះបណ្ដាលកសិករចំនួន ៧លើក មានកសិករចូលរួមចំនួន ២៤០នាក់ (ស្រី១៣៩នាក់) ចែកពូជស្រូវចំណាត់ថ្នាក់ពូជស្រូវសុទ្ធល្អសរុបចំនួន ៨៧៥គ.ក្រដល់កសិករនៅខេត្តត្បូងឃ្មុំចំនួន ៤៥០គ.ក្រ និងខេត្តឧត្តរមានជ័យចំនួន ៤២៥គ.ក្រសម្រាប់ការងារបង្កបង្កើនផលស្រូវក្នុងឆ្នាំ២០២០ ជាពូជធានានូវភាពសុទ្ធល្អ និងទិន្នផលខ្ពស់

- បានចងក្រងនិងបោះពុម្ពសៀវភៅរបាយការណ៍សង្ខេបសមិទ្ធផលនៃការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាកសិកម្មឆ្នាំ២០១៩ និងទិស ដៅសម្រាប់ឆ្នាំ២០២០ ព្រមទាំងបានផ្ដល់ជូននាយកដ្ឋានផែនការនិងស្ថិតិចំនួន ៤០០ក្បាល ទុកចែកជូនថ្នាក់ដឹកនាំ អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត និងអ្នកពាក់ព័ន្ធដទៃទៀត

- បានចូលរួមសសេរអត្ថបទវិទ្យាសាស្ត្រ និងត្រូវបានទទួលឲ្យបោះពុម្ពក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រអន្តរជាតិចំនួន ២អត្ថបទ

- បានបោះពុម្ពឯកសារឡើងវិញចំនួន ១៣ ៨២០ច្បាប់ និងបែងចែកឯកសារសរុបចំនួន ៤ ៦៨០ច្បាប់។ អ្នកប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យាតាមរយៈគេហទំព័រ http://www.cardi.org.kh មានចំនួនសរុប ៦៦៣ ៦២៨នាក់។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៩-២០២០ សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យាសាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម

- គ្រប់មហាវិទ្យាល័យ និងឆ្នាំសិក្សាមូលដ្ឋានបាននិងកំពុងដំណើរការបង្រៀននិស្សិតពីចម្ងាយតាមរយៈប្រព័ន្ធអេឡិចត្រូនិក និងតាមអនឡាញសម្រាប់កម្មវិធីសិក្សាឆមាសទី២ ឆ្នាំសិក្សា ២០១៩-២០២០

- បន្តការងារសិក្សាពិសោធន៍ស្រាវជ្រាវរបស់ខ្លួនលើប្រធានបទមួយចំនួនដូចជាការពិសោធន៍លើចំណីសត្វ ការចិញ្ចឹមសត្វ ពិសោធន៍លើអតិសុខុមប្រាណសាស្ត្រ ប៉ារ៉ាសិត ការកែច្នៃស្រាព្រើង ការបណ្ដុះឃីស វិធីសាស្ត្រសម្ងួតល្ហុង ការផលិតម្សៅខ្ទី ការស្វែងរកមីក្រូសរីរាង្គនៅក្នុងផលិតផលផ្សេងៗ និងការសិក្សាទំនាក់ទំនងរវាងការធ្វើចំណាកស្រុកនិងបម្រែបម្រួលនៃប្រព័ន្ធកសិកម្មនិងបរិស្ថាន នៅខេត្តកំពង់ធំនិងតាកែវ

- គ្រប់មហាវិទ្យាល័យបន្តអប់រំបំពាក់បំប៉នដល់សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ អំពីវិធីសាស្ត្របង្រៀនពីចម្ងាយនៅក្នុងមហាវិទ្យាល័យរបស់ខ្លួន ហើយលោកគ្រូអ្នកគ្រូមួយចំនួនបានសិក្សាជាមួយបណ្ដាញសាកលវិទ្យាល័យនិយាយភាសាបារាំង (AUF) អំពីវិធីសាស្ត្របង្រៀនពីចម្ងាយតាមរយៈអនឡាញ (Hybrid; Digital និង E-learning) និង ការប្រើប្រាស់បណ្ណាល័យឌីជីថល ផងដែរ

- បានជួបពិភាក្សាការងារជាមួយក្រុមហ៊ុនកូរ៉េ Han Seung ផ្គត់ផ្គង់សម្ភារស្រោចស្រព កម្រាលប្លាស្ទិក និង greenhouse។ ក្រុមហ៊ុននឹងជួយផ្ដល់សម្ភារទាំងនេះដល់និស្សិតសម្រាប់ធ្វើការពិសោធន៍។ សហការជាមួយអង្គការដៃគូរ LOUVAIN Cooperation (LC) រៀបចំបង្កើតគម្រោងសំណើស្រាវជ្រាវអំពីការប្រែប្រួលការអនុវត្តកសិកម្មគេ្យត្យបរិស្ថានលើការកាត់បន្ថយជំងឺគ្រុនចាញ់ក្នុងខេត្តកំពង់ធំ និងខេត្តកំពង់ចាម។ រៀបចំអនុស្សរណៈយោគយល់រវាងសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងក្រុមហ៊ុន CAST CO., LTD នៃសាធារណរដ្ឋកូរ៉េ និង បានបង្កើតកិច្ចសហប្រតិបត្តិការពហុភាគីជាមួយក្រុមហ៊ុន BIO Co.LTD

- បានចុះតាមដានប្រព័ន្ធចម្រោះជីវឧស្ម័នតាមបណ្ដាកសិដ្ឋានចិញ្ចឹមជ្រូកនៅខេត្តកំពង់ស្ពឺ និងបានចុះទៅដំឡើងឧបករណ៍វាស់វែងគុណភាពឧស្ម័ន និងតម្រូវការភ្លើងនៅរោងចក្រកែច្នៃម្សៅមីនៅខេត្តត្បូងឃ្មុំ។

### ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៩-២០២០ សរុបចំនួន ១ ០៨៨នាក់ (ស្រី៤៥៤នាក់) លើជំនាញៈ កសិកម្ម ជលផល ព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ សាកវប្បកម្ម ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិ-ឧស្សាហកម្ម និងសុរិយោដី

- បានរៀបចំកិច្ចប្រជុំគ្រប់ដេប៉ាតេម៉ង់ចំនួន ១៣ដោយលើកយកកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្ររងដើម្បីពិនិត្យ និងកែលម្អគម្រោងមុខវិជ្ជានីមួយៗចំនួន ១៣លើក

- បានចូលរួមវគ្គបណ្ដុះបណ្ដាលកសិករ និងអាណាព្យាបាលកុមារមត្តេយ្យស្តីពីអាហារូបត្ថម្ភ

- បានចុះអនុស្សរណៈនៃការយោគយល់គ្នារវាងវិទ្យាស្ថាន និងអង្គមូលនិធិចក្ខុខ្មែរ

- បានទៅទស្សនកិច្ចសិក្សាកសិដ្ឋានចិញ្ចឹមគោយកទឹកដោះក្នុងឧទ្យាន គេជោសែន ឫស្សីត្រឹប នៅខេត្តព្រះវិហារ ចំនួន ១លើក

- បានចុះសិក្សាពីលទ្ធភាពឫស្សីដែលអាចយកមកផលិតម្សៅនៅខេត្តព្រះសីហនុ និងចុះសិក្សាទីតាំងសម្រាប់និស្សិតចុះកម្មសិក្សានៅខេត្តតាកែវ

- បានចុះសិក្សាពីលទ្ធភាពបូមទឹកដោយប្រើចរន្តទឹកហូរពីធម្មជាតិ

- បានបន្តការស្រាវជ្រាវលើ ផ្កាអ័រគីដេ ចេក ស្វាយចន្ទី ត្រីជាដើម។

### ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៩-២០២០ សរុបចំនួន ៧១៩នាក់ (ស្រី២៨៤នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- បានដំណើការកែសារណាបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មផ្នែកអាហារូបករណ៍ជំនាន់ទី១៤ និងផ្នែកបណ្តុះបណ្តាលបន្តជំនាន់ទី១៧

- បានបើកវគ្គបណ្តុះបណ្តាលការដាំដុះបន្លែលើទឹក (Hydroponics) ដល់និស្សិតជំនាញសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទសរុបចំនួន ១៦នាក់

- បានពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- បានពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- បានពិសោធន៍សាកល្បងផលិតមេជី Lacto Bacellus និងពិសោធន៍ឥទ្ធិពលមេជីលើការលូតលាស់ដំណាំស្ពៃក្តោប និងស្រូវ

- បានពិសោធន៍ដំណាំនៅលើទឹកដោយប្រើប្រាស់ប្រភពទឹកពីអាងចិញ្ចឹមត្រីនៅស្ថានីយពិសោធន៍ផលផលរបស់វិទ្យាស្ថាន

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហម

- បានធ្វើការពិសោធន៍លើការចិញ្ចឹមបង្កងពូជអូស្ត្រាលីចំនួន ១៦៥គូរ និង២៥០កូន

- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ប៉េងប៉ោះ ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្ទេស

- បានបណ្តុះបណ្តាលមន្ត្រីសហគមន៍សំបូរមានជ័យស្តីពីការចម្រាញ់ប្រេងស្លឹកគ្រៃ

- បានសហការជាមួយ DTRA (Defence Threat Reduction Agency) ក្នុងការបើកវគ្គបណ្តុះបណ្តាលចំនួន៣វគ្គ ដូចជា ជំងឺប៉ារ៉ាស៊ីតសត្វឆ្លងមកមនុស្សនៅកម្ពុជា អេពីដេមីសាស្ត្រនៃជំងឺផ្តាសាយបក្សី ជីវសុវត្ថិភាពសម្រាប់ជំងឺហ្សូណូស និងជំងឺសត្វឆ្លងដែនដល់និស្សិតជំនាញវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រ។

### ១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានសិក្សាមាឌឈើកៅស៊ូតាមក្លូននីមួយៗនៅឡូត៍ពិសោធន៍ក្លូន IRAA05

- បានវាស់ទំហំដើមកៅស៊ូនៅឡូត៍ពិសោធន៍ IRAA011 និង IRAA012

- បានស្រង់ទិន្នន័យជ័រកៅស៊ូនៅចម្ការពិសោធន៍សក្តានុពលទិន្នផលលើប្រព័ន្ធចង្វាក់ចៀរជ័រ d4 ចំនួន ៩ចម្ការពិសោធន៍ និងចម្ការពិសោធន៍ប្រព័ន្ធចៀរជ័រចង្វាក់រង្វើល d3 d4 d5 d6 ចំនួន ២ចម្ការពិសោធន៍

- បានរៀបចំលាយថ្នាំរំញោច Ethephon តាមកំហាប់ខុសៗគ្នា ដើម្បីលាបរំញោចតាមពិធីសាពិសោធន៍

- បានវិភាគរកស្តង់ដារសរីរសាស្ត្រទឹកជ័រលើប៉ារ៉ាម៉ែត្រ Inorganic Phosphorus (Pi), Sucrose (Suc), និង Thiol (RSH) ចំនួន ៤លើកដើម្បីផ្ទៀងផ្ទាត់សារជាតុគីមី

- បានបាញ់ថ្នាំ Dithan M45 ការពារ និងព្យាបាលជំងឺកូនកៅស៊ូ

- បានដាក់ជីលើកទី១គ្រប់ចំការកៅស៊ូដាំឆ្នាំ២០១៦-២០១៩ និងចម្ការពិសោធន៍ជីកៅស៊ូផ្តល់ផល

- បានវាស់ទំហំដើមសម្រាប់បើកមុខចៀរថ្មី និងរៀបចំសម្ភារបំពាក់ដើម

- បានថែទាំឡូត៍កៅស៊ូចៀរជ័រដូចជាលាបថ្នាំរំញោច និងលាបខ្លាញ់គោ លើដើមកៅស៊ូចៀរជ័រ។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាធ្វើការដាំដុះបានចំនួន ១ ៥៧៤ ៨១៨ហ.ត ស្មើនឹង៦០,៨៥% នៃផែនការចំនួន ២ ៥៨៨ ១៣០ហ.ត។ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើយន្តការ និងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់ និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការតាមដានវាយតម្លៃអំពីការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈឺក្នុងតំបន់ផ្ទុះជំងឺ បទល្មើសព្រៃឈើ និងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងក៏បានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូល

ថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

ជារួម ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយនូវរាល់ការលំបាកផ្សេងៗប្រកបដោយមោទនភាព ពិតមែនតែនៅមានបញ្ហាប្រឈមខ្លះៗក៏ដោយ។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្មនៅក្នុងរដូវវស្សាឆ្នាំ២០២០
- បន្តធ្វើការពិនិត្យសន្និធិស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩
- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ
- ត្រៀមលក្ខណៈមានដូចជាៈ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មសម្រាប់ការងារបង្កបង្កើនផល
- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

### ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទរួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង
- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន
- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត
- បន្តការតាមដានស្ថានភាពជំងឺស្វាយណូសជាប្រចាំនៅតាមបណ្តារាជធានី-ខេត្ត
- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យ កន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) និងជំងឺ A(H1N1)
- បន្តអនុវត្តការបង្កាត់ពូជគោ និងជ្រូកដោយសិប្បនិម្មិត។

### ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់
- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើឲ្យចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឲ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋាន ឲ្យយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹង លេខ១៣៤៨ សជណ.កជ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឲ្យបានជ្រួតជ្រាបដល់មូលដ្ឋាន ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីរាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

**៤ ផ្នែកជលផល**

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេច លេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ**

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ៕

ថ្ងៃចន្ទ ១រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**